ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

មន្ទីរសុខាភិបាលរាជធានីភ្នំពេញ
ក្រុមលទ្ធកម្ម
លេខ : ០.៣៤.....កល

ប្រធានវិនិច្ឆ័យត្រឹមត្រូវ
អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

# សេចក្តីជូនដំណឹង
## ស្តីពី
## ការងារជួសជុលពង្រីកអគារនៅស្រុកប្រតិបត្តិ មន្ទីរពេទ្យបង្អែក, មណ្ឌលសុខភាព និងប៉ុស្តិ៍សុខភាព ឆ្នាំ២០២០ ជូនមន្ទីរសុខាភិបាលរាជធានីភ្នំពេញ

**មន្ទីរសុខាភិបាលរាជធានីភ្នំពេញ** សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល)ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យបានជ្រាបថា មន្ទីរសុខាភិបាលរាជធានីភ្នំពេញ នឹងដាក់ឱ្យដេញថ្លៃជាសាធារណៈ ដើម្បីជ្រើសរើសអ្នកទទួល**ការងារជួសជុលពង្រីកអគារនៅស្រុកប្រតិបត្តិ មន្ទីរពេទ្យបង្អែក មណ្ឌលសុខភាព និងប៉ុស្តិ៍សុខភាព ឆ្នាំ២០២០ ជូនមន្ទីរសុខាភិបាលរាជធានីភ្នំពេញ ។**

មន្ទីរសុខាភិបាលរាជធានីភ្នំពេញ បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ។ ឯកសារដេញថ្លៃមានដាក់លក់នៅមន្ទីរសុខាភិបាលរាជធានីភ្នំពេញ ដែលមានអាសយដ្ឋាន ផ្លូវលេខ២០១១ (ឧកញ៉ា ទ្រី ហេង) ភូមិច្រេស សង្កាត់គោកឃ្លាង ខណ្ឌសែនសុខ រាជធានីភ្នំពេញ ចាប់ពីថ្ងៃទី ..០៣.. ខែ..សីហា... ឆ្នាំ២០២០ តទៅរៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទាក់ទងលេខ ០៨៨ ៨៥០ ៥៥៥៥ ) ។

ឯកសារដេញថ្លៃដែលបានបំពេញរួច ត្រូវប្រគល់ជូនក្រុមលទ្ធកម្មមន្ទីរសុខាភិបាលរាជធានីភ្នំពេញ យ៉ាងយូរបំផុតត្រឹមថ្ងៃទី...០៤... ខែ..កញ្ញា........ឆ្នាំ២០២០ វេលាម៉ោង ..៩:៣០ នាទី.....។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅមន្ទីរសុខាភិបាលរាជធានីភ្នំពេញ តាមអាសយដ្ឋានខាងលើ វេលាម៉ោង..៩:៣០... ថ្ងៃទី ..០៤..... ខែ .....កញ្ញា........ ឆ្នាំ២០២០ ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់ ។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយក្រុមលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ ។

ថ្ងៃ..........................ខែ.....................ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ..៣១..... ខែ..កក្កដា.. ឆ្នាំ២០២០
**ប្រធានមន្ទីរសុខាភិបាលរាជធានីភ្នំពេញ**
**និងជាប្រធានក្រុមលទ្ធកម្ម**

**មេធាវី ង៉ែត ឌី មានហេង**

3

ចម្លងជូន ៖
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ)
-អង្គភាពប្រឆាំងអំពើពុករលួយ
-ឯកសារ-កាលប្បវត្តិ

៤